01376061
Declassified to Public
05 April 2019

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 12 / 01 / 2017
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

E443/6

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សម្ងាត់ / Confidential / Confidentiel

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៧

**ជូនចំពោះ៖** **ភាគីទាំងអស់នៃសំណុំរឿង ០០២**

**ពី៖** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន៖** **លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ៖** **សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា និងមេធាវីការពារក្តី ខៀវ សំផន សុំឱ្យទទួលយករូបថតដែលសាស្ត្រាចារ្យ Walter HEYNOWSKI (2-TCW-946) បានផ្តល់ជូន**

១. នៅថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៧ អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីថា អង្គជំនុំជម្រះទទួលបានរូបថតអ្នកជាប់ឃុំនៅមន្ទីរសន្តិសុខ ស-២១ ដែលមានចំនួនប្រហែល ៥០០ សន្លឹក ពីសាស្ត្រាចារ្យ Walter HEYNOWSKI (2-TCW-946) (ឯកសារ E443/2/1)។ អង្គភាពបណ្ណាសារ (RAU) បានពិនិត្យរូបថតនៅមន្ទីរសន្តិសុខ ស-២១ ទាំងនេះ ដោយមានវត្តមានក្រឡាបញ្ជី ហើយអង្គជំនុំជម្រះបានណែនាំឱ្យអង្គភាពបណ្ណាសារដាក់រូបថតដែលអាចថតស្កេន ឬ ថតបានប្រកបដោយសុវត្ថិភាពទៅក្នុងផ្នែកផ្ទុកឯកសាររួម (Shared Folder)។ អង្គជំនុំជម្រះបានណែនាំឱ្យភាគីដាក់សេចក្តីសន្និដ្ឋានផ្ទាល់មាត់ទៅលើសំណើតាមវិធាន ៨៧(៤)

នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងរូបថតនៅមន្ទីរសន្តិសុខ ស-២១ ទាំងនេះ នៅថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៧ (ឯកសារ E443/2/1 កថាខណ្ឌ ៥)។

២. ក្នុងអំឡុងពេលសវនាការថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៧ សហព្រះរាជអាជ្ញាបានស្នើសុំឱ្យទទួលយកជាភស្តុតាងនូវរូបថតនៅមន្ទីរសន្តិសុខ ស-២១ ទាំងអស់ដែលបានដាក់ក្នុងថែកផ្ទុកឯកសាររួម ហើយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានគាំទ្រសំណើនេះ (ប្រតិចារឹកសវនាការ ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៧ ទំព័រ ៣៧-៣៩ (សេចក្តីព្រាង))។ ពុំមានក្រុមមេធាវីការពារក្តីណាមួយជំទាស់ទៅនឹងសំណើនេះទេ (ប្រតិចារឹកសវនាការ ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៧ ទំព័រ ៣៩-៤០ (សេចក្តីព្រាង))។ មេធាវីការពារក្តី ខៀវ សំផន បានស្នើសុំឱ្យទទួលយករូបថតបន្ថែមទៀតធ្វើជាភស្តុតាងផងដែរ (ប្រតិចារឹកសវនាការ ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៧ ទំព័រ ៤០-៤២ (សេចក្តីព្រាង))។ អង្គភាពបណ្ណាសារបានថតរូបទាំងនេះក្នុងពេលថតស្កែនចេញពីសៀវភៅពណ៌ទឹកក្រូចដែលជាកំណត់ត្រាប្រចាំថ្ងៃអំពីអ្នកជាប់ឃុំ ដែលទទួលបានពីសាស្ត្រាចារ្យ HEYNOWSKI (2-TCW-946) ផ្ញើជូនអង្គជំនុំជម្រះ។ ភាគីផ្សេងទៀតពុំបានជំទាស់ទៅនឹងសំណើនេះទេ ទោះបីសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានកត់សម្គាល់ថា ពួកគេពុំបានឃើញរូបថតទាំងនេះក៏ដោយ (ប្រតិចារឹកសវនាការ ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៧ ទំព័រ ៤២-៤៣ (សេចក្តីព្រាង))។ អង្គជំនុំជម្រះទទួលបានរូបថតនៃសៀវភៅកំណត់ត្រាប្រចាំថ្ងៃអំពីអ្នកជាប់ឃុំពីអង្គភាពបណ្ណាសារ ហើយ នៅពេលនេះបានដាក់បញ្ចូលទៅក្នុងអនុថែក 5 នៃថែកផ្ទុកឯកសាររួម (Sub-Folder 5)។ មេធាវីការពារក្តី ខៀវ សំផន បានបញ្ជាក់ថា រូបថតទាំងនេះគឺជារូបថតដែលពួកគាត់បានស្នើសុំឱ្យទទួលយកជាភស្តុតាង (អ៊ីម៉ែលឆ្លើយតបពីមេធាវីការពារក្តី ខៀវ សំផន ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៧)។

៣. យោងតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង នៅគ្រប់ដំណាក់កាលទាំងអស់នៃការជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង អាចទទួលយកភស្តុតាងទាំងឡាយណាដែលអង្គជំនុំជម្រះយល់ឃើញថាមានប្រយោជន៍សម្រាប់ការបញ្ជាក់ការពិត ក្នុងករណីដែលភស្តុតាងនោះបំពេញទៅតាមបទដ្ឋាន *បឋម* នៃភាពពាក់ព័ន្ធ ភាពអាចជឿជាក់បាន និងយថាភាព ដែលតម្រូវដោយវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះសម្រេចលើសំណើសុំឱ្យទទួលយកភស្តុតាងថ្មី ស្របតាមលក្ខណៈវិនិច្ឆ័យ ដូចមានចែងនៅក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។

៤. អង្គជំនុំជម្រះរំឭកថា នៅថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានទទួលយកធ្វើជាឯកសារភស្តុតាងនូវសៀវភៅពណ៌ទឹកក្រូចដែលជាកំណត់ត្រាប្រចាំថ្ងៃអ្នកជាប់ឃុំ ដែលលោកសាស្ត្រាចារ្យ HEYNOWSKI (2-TCW-946) បានផ្តល់ជូន ពីព្រោះថា សៀវភៅនេះ "ពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹងទីតាំងឧក្រិដ្ឋកម្មមួយកន្លែងដែលស្ថិតនៅក្នុងវិសាលភាពនៃការជំនុំជម្រះក្តីនាពេលបច្ចុប្បន្ននេះ (ឯកសារ E443/3 កថាខណ្ឌ ៣)។ អង្គជំនុំជម្រះកត់សម្គាល់ថា រូបថតនៅមន្ទីរសន្តិសុខ ស-២១ ក៏ពាក់ព័ន្ធផងដែរជាមួយនឹងទីតាំងឧក្រិដ្ឋកម្មមួយកន្លែងដែលស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២។ បន្ថែមពីលើនេះទៀត ទាំងរូបថតនៅមន្ទីរសន្តិសុខ ស-២១ ទាំងរូបថតនៃសៀវភៅកំណត់ត្រាប្រចាំថ្ងៃអំពីអ្នកជាប់ឃុំ គឺពាក់ព័ន្ធជាមួយនឹងភស្តុតាងដែលមាននៅក្នុងសំណុំរឿងរួចហើយ ពិសេសសៀវភៅពណ៌ទឹកក្រូចកំណត់ត្រាប្រចាំថ្ងៃអំពីអ្នកជាប់ឃុំ ដែលត្រូវបានទទួលយករួចហើយ ដោយបានដាក់លេខឯកសារ E3/10770។

៥. ហេតុនេះ អង្គជំនុំជម្រះយល់ព្រមតាមសំណើរបស់សហព្រះរាជអាជ្ញា និងសំណើរបស់មេធាវីការពារក្តី ខៀវ សំផន ដែលស្នើសុំឱ្យទទួលយករូបថតទាំងនេះធ្វើជាភស្តុតាង និងដាក់រូបថតទាំងនោះជាប្រភេទឯកសារ E3 ដូចខាងក្រោម ទៅតាមអនុផ្នែកនៅក្នុងឃ្លាំងផ្ទុកឯកសាររួមដែលរក្សាទុករូបថតទាំងនេះ។ អនុផ្នែក 1a ដាក់ជាឯកសារលេខ E3/10785, អនុផ្នែក 1b ដាក់ជាឯកសារលេខ E3/10786, អនុផ្នែក 2 ដាក់ជាឯកសារលេខ E3/10787, អនុផ្នែក 4 ដាក់ជាឯកសារលេខ E3/10788 និង អនុផ្នែក 5 ដាក់ជាឯកសារលេខ E3/10789។